ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ:...០៩៣ ប្រ.ក.....ប.ស្ថ

# ប្រកាស

## ស្តីពី

## ការទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ «ប្រាសាទភ្នំក្រៀល» នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ស្ថិតនៅភូមិភ្នាក់រលើក ឃុំឆ្មា ស្រុកជ័យសែន ខេត្តព្រះវិហារ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃ «ព្រៃឡង់»
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១._**

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ **«ប្រាសាទភ្នំក្រៀល»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ស្ថិតនៅភូមិភ្នាក់រលើក ឃុំឆ្មា ស្រុកជ័យសែន ខេត្តព្រះវិហារ។



អគារមរតកតេជោ ជីឡុយលេខ៥០៣ ផ្លូវកៅស៊ូមហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៤ ០០៤/ ០២៣ ២១៤ ០០៦

**ប្រការ២._**

សហគមន៍តំបន់ការពារធម្មជាតិ **«ប្រាសាទភ្នំក្រៀល»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» មានផ្ទៃដីសរុបទំហំ **២,២៦៦.៣៥ ហិកតា** (ពីរពាន់ពីររយហុកសិបប្រាំមួយក្បៀសសាមសិបប្រាំហិកតា) ដូចមានផែនទី ភ្ជាប់ជាឧបសម្ព័ន្ធកំណត់ដោយចំណុចគោលដែលមាននិយាមកា(Datum: WGS1984) ដូចក្នុងតារាងខាងក្រោម៖

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 553096 | 1489448 | 15 | 555528 | 1497149 |
| 2 | 553258 | 1489091 | 16 | 555412 | 1497140 |
| 3 | 553410 | 1488583 | 17 | 555243 | 1497027 |
| 4 | 553628 | 1488407 | 18 | 554886 | 1497005 |
| 5 | 553681 | 1488308 | 19 | 554769 | 1497108 |
| 6 | 554465 | 1488315 | 20 | 554710 | 1497065 |
| 7 | 554888 | 1488986 | 21 | 554485 | 1497115 |
| 8 | 555464 | 1489392 | 22 | 554354 | 1497214 |
| 9 | 555193 | 1492116 | 23 | 554120 | 1497148 |
| 10 | 556343 | 1493079 | 24 | 554008 | 1497123 |
| 11 | 556781 | 1497470 | 25 | 553818 | 1497008 |
| 12 | 555867 | 1500068 | 26 | 553536 | 1494790 |
| 13 | 554898 | 1499819 | 27 | 554464 | 1494404 |
| 14 | 555664 | 1497001 | 28 | 554187 | 1493243 |

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| A | 552754 | 1497074 | K | 552331 | 1497008 |
| B | 552961 | 1497192 | L | 552248 | 1496842 |
| C | 553100 | 1497369 | M | 552371 | 1496720 |
| D | 553046 | 1497633 | N | 552723 | 1496987 |
| E | 552978 | 1497769 | O | 552674 | 1496957 |
| F | 552808 | 1497778 | P | 552631 | 1496975 |
| G | 552709 | 1497666 | Q | 552591 | 1496949 |
| H | 552648 | 1497495 | R | 552622 | 1496886 |
| I | 552523 | 1497346 | S | 552583 | 1496836 |
| J | 552460 | 1497179 | T | 552454 | 1496788 |

**ប្រការ៣._**

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«ប្រាសាទភ្នំក្រៀល»** ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤._**

សហគមន៍តំបន់ការពារធម្មជាតិ **«ប្រាសាទភ្នំក្រៀល»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ **«ប្រាសាទភ្នំក្រៀល»** ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ និងប្រធានសហគមន៍តំបន់ការពារធម្មជាតិ **«ប្រាសាទភ្នំក្រៀល»** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

ក្រសួងបរិស្ថាន

**សាយ សំអាល់**

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះវិហារ
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទី ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិព្រៃសាលក្បាលត្រៀល ក្នុងដែនជម្រកសត្វព្រៃ " ព្រៃឡង់ "
ភូមិសាស្ត្រភូមិត្បាក់លើក ឃុំទ្វា ស្រុកជ័យសែន ខេត្តព្រះវិហារ ផ្ទៃដី២២៦៦,៣៥ហិកតា




| ID | X | Y |
|---|---|---|
| 1 | 553090 | 1489448 |
| 2 | 553258 | 1489091 |
| 3 | 553410 | 1488583 |
| 4 | 553628 | 1488407 |
| 5 | 553681 | 1488308 |
| 6 | 554465 | 1488315 |
| 7 | 554889 | 1488960 |
| 8 | 555464 | 1489392 |
| 9 | 555193 | 1492116 |
| 10 | 556343 | 1493079 |
| 11 | 556781 | 1497470 |
| 12 | 555867 | 1500068 |
| 13 | 554896 | 1499819 |
| 14 | 555664 | 1497001 |
| 15 | 555528 | 1497149 |
| 16 | 555412 | 1497140 |
| 17 | 555243 | 1497027 |
| 18 | 554886 | 1497005 |
| 19 | 554769 | 1497106 |
| 20 | 554710 | 1497065 |

| No | X | Y |
|---|---|---|
| A | 552754 | 1497074 |
| B | 552961 | 1497192 |
| C | 553100 | 1497369 |
| D | 553046 | 1497633 |
| E | 552978 | 1497769 |
| F | 552808 | 1497778 |
| G | 552709 | 1497666 |
| H | 552648 | 1497495 |
| I | 552523 | 1497346 |
| J | 552460 | 1497179 |
| K | 552331 | 1497008 |
| L | 552248 | 1496842 |
| M | 552371 | 1496720 |
| N | 552723 | 1496887 |
| O | 552674 | 1496957 |
| P | 552631 | 1496975 |
| Q | 552591 | 1496949 |
| R | 552622 | 1496886 |
| S | 552583 | 1496836 |
| T | 553454 | 1496789 |

| ID | X | Y |
|---|---|---|
| 21 | 554485 | 1497115 |
| 22 | 554354 | 1497214 |
| 23 | 554120 | 1497148 |
| 24 | 554056 | 1497123 |
| 25 | 553818 | 1497008 |
| 26 | 553536 | 1494790 |
| 27 | 554464 | 1494404 |
| 28 | 554187 | 1493243 |